**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

លេខ: ០០១ ស.ណ.រ ក.ជ.អ.ច.

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេសជីវៈចម្រុះ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន
## និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៤១៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ នៃព្រះរាជក្រឹត្យលេខនស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១១៤អនក្រ/បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥អនក្រ/បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីសម្រេចរាជរដ្ឋាភិបាលលេខ៥៤ សសរ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- យោងតាមសំណើរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសជីវៈចម្រុះ ដែលសរសេរជាអក្សរកាត់ថា **ក.ប.ជ.** និងជាភាសាអង់គ្លេស Biodiversity Technical Working Group (BTWG) ដើម្បីសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (**ក.ជ.អ.ច.**) សម្រាប់ការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

**ក.ប.ជ.** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម ទិន ពន្លក | អគ្គលេខាធិការ នៃក.ជ.អ.ច. | ប្រធាន |
| ២. លោកជំទាវ ចាន់ សុម៉ាលី | អគ្គលេខាធិការរង នៃក.ជ.អ.ច. | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. លោក ម៉េង មុនីរក្ស | ប្រធាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | អនុប្រធានទី២ |
| ៤. ឯកឧត្តម គឹម ណុង | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា | អនុប្រធានទី៣ |
| ៥. លោក អ៊ុក ណាវ៉ាន់ | អគ្គនាយករង នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ក្រសួងបរិស្ថាន | សមាជិក |
| ៦. លោក ពុទ្ធ សុរិទ្ធី | អគ្គនាយករង នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ៧. លោក កុច សុវាទ | អគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន | សមាជិក |
| ៨. លោក គី ខេមលីន | អគ្គនាយករង នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៩. ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក កោសា | នាយក នាយកដ្ឋានអភិវឌ្ឍន៍ នៃក្រសួងការពារជាតិ | សមាជិក |
| ១០. លោក យោង ចាន់សុភារ | ប្រធាននាយកដ្ឋានអង្គការសហប្រជាជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

| | | |
|---|---|---|
| ១១.លោក អ៊ុក វិបុល | ប្រធាននាយកដ្ឋានអភិរក្សជលផល នៃរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២.លោក សេង ប៊ុនឡឿន | ប្រធាននាយកដ្ឋានរៀបចំដែនដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | សមាជិក |
| ១៣.លោក យឹម ជុង | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៤.លោក ពេជ ច័ន្ទ | ប្រធាននាយកដ្ឋានកិច្ចការប្រេកួតប្រជែង អគ្គនាយកដ្ឋានកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៥.លោក អប់ រ៉ាឌី | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៦.លោក អោ សៀម | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៧.លោក ប្រុក ណូរីដា | ប្រធាននាយកដ្ឋានផែនការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៨.លោក សាន វណ្ណរិទ្ធ | ប្រធាននាយកដ្ឋានផែនការវិនិយោគ នៃក្រសួងផែនការ | សមាជិក |
| ១៩.លោក គ្រី ម៉ះផល | អនុប្រធាននាយកដ្ឋានសត្វព្រៃនិងជីវចម្រុះ នៃរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២០.លោក ទូច ជា | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២១.លោកប៉ក់ កាណាដា | អនុប្រធានវិទ្យាសាស្ត្រស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ សត្វព្រៃ នៃរដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២២.លោក ម៉ូញ ទី | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ទេសចរណ៍ នៃក្រសួងទេសចរណ៍ | សមាជិក |
| ២៣.លោក ថាច់ សុវណ្ណា | អនុប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក នៃក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២៤.លោក ទឹម ភីយ៉ារី | អនុប្រធាននាយកដ្ឋានផែនការនិងស្ថិតិ នៃក្រសួងកិច្ចការនារី | សមាជិក |
| ២៥.លោក កុល ផាន់ណា | អនុប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងព័ត៌មាន | សមាជិក |

R A pr.

| | | |
|---|---|---|
| ២៦.លោក ហាប់ ចាន់ធា | អនុប្រធាននាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៧.លោក សាន ចំរើន | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្ត នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២៨.លោក ថៃ ពិសិដ្ឋ | អនុប្រធាននាយកដ្ឋានបណ្តាគម្រោង និងកម្មវិធី នៃគណៈកម្មាធិការជាតិទន្លេមេគង្គ | សមាជិក |
| ២៩.លោកវេជ្ជបណ្ឌិត ម៉ឹង វណ្ណារុំ | ប្រធានមជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របុរាណ នៃក្រសួងសុខាភិបាល | សមាជិក |
| ៣០.លោកបណ្ឌិត សេង វ៉ាង | នាយករងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម | សមាជិក |
| ៣១.លោក ថៃ អៀងលី | អនុប្រធានដេប៉ាតឺម៉ង់ជីវវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣២.លោក គឹម សុបិន្ត | នាយករងសាលាក្រោយឧត្តម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | សមាជិក |
| ៣៣.លោក ឈុន ប៊ុនណារ៉ា | អនុប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី នៃលេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |
| ៣៤.លោកស្រី សុខ សុទ្ធាវី | ប្រធានរដ្ឋបាល នៃសភាពាណិជ្ជកម្ម | សមាជិក |
| ៣៥.លោក ឃុំ ពៀក | ប្រធានសហគមន៍ជនជាតិដើមភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣៦.លោកស្រី កែន បូព្រាង | អនុប្រធាននាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋាន ក.ជ.អ.ច. | លេខាធិការ។ |

**ប្រការ៣**..

**ក.ប.ជ**. មានភារកិច្ច ដូចខាងក្រោម៖

- ផ្តល់យោបល់បច្ចេកទេសសម្រាប់ការរៀបចំ ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាពគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងក្របខ័ណ្ឌការងារ ស្តីពីជីវៈចម្រុះ ការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ ជីវសុវត្ថិភាព ការទូទាត់ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ការអភិរក្សក្រៅតំបន់ ព្រមទាំងបង្កើតមធ្យោបាយ ឬវិធានដើម្បីជំរុញការអនុវត្ត
- ផ្តល់យោបល់បច្ចេកទេស និងគោលនយោបាយក្នុងការរៀបចំឯកសារជំហររបស់រដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងអភិរក្សជីវៈចម្រុះនៅកម្ពុជា
- សម្របសម្រួល រៀបចំ ប្រមូល ចងក្រង និងធ្វើបច្ចុប្បន្នភាពព័ត៌មាន-ទិន្នន័យ និងរបាយការណ៍ជាតិពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងអភិរក្សជីវៈចម្រុះនៅកម្ពុជា
- ផ្តល់ការណែនាំលើកិច្ចការបច្ចេកទេសជាក់លាក់សម្រាប់ដោះស្រាយបញ្ហា និងវិធានការសម្រាប់អនុវត្តការងារពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះនៅកម្ពុជា
- ជំរុញការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន-ទិន្នន័យ និងចំណេះដឹងស្តីពីការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះជាមួយបណ្តាក្រសួងស្ថាប័ន អង្គការដៃគូ គ្រឹះស្ថានសិក្សា វិស័យឯកជន និងអ្នកពាក់ព័ន្ធ

R. A. por. N B

- ជំរុញ ពង្រឹង និងពង្រីកបណ្តាញការងារ និងបញ្ជ្រាបការងារគ្រប់គ្រង និងអភិរក្សជីវៈចម្រុះទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យនៅក្នុងស្ថាប័នសមាជិករៀងៗខ្លួន
- ជំរុញ និងលើកកម្ពស់ការយល់ដឹងក្នុងក្រសួងស្ថាប័នសាមី អង្គការដៃគូជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ គ្រឹះស្ថានអប់រំ វិស័យឯកជន ជនជាតិដើមភាគតិច ស្តីពីជីវៈចម្រុះ និងលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវអំពីតម្លៃ និងគុណតម្លៃប្រព័ន្ធអេកូឡូស៊ី ការទូទាត់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងការអភិរក្សក្រៅតំបន់
- ចូលរួមតាមដាន និងវាយតម្លៃការអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ពិធីសារ កិច្ចព្រមព្រៀង និងសេចក្តីសម្រេចពាក់ព័ន្ធនានាសម្របសម្រួល និងចូលរួមកៀរគរធនធានសម្រាប់អនុវត្តគម្រោង និងកម្មវិធីដើម្បីគាំទ្រដល់កិច្ចការគ្រប់គ្រង និងអភិរក្សជីវៈចម្រុះនៅថ្នាក់ជាតិ តំបន់ និងសកល
- សម្របសម្រួល រៀបចំ និងចូលរួមទិវាជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងជីវៈចម្រុះ
- ដើរតួនាទីជាជនបង្គោលសម្រាប់ការងារពាក់ព័ន្ធនឹងជីវៈចម្រុះ ក្នុងនាមក្រសួងស្ថាប័នរបស់ខ្លួន
- សម្របសម្រួល និងចូលរួមកសាងសមត្ថភាព ការបណ្តុះបណ្តាល សិក្ខាសាលា និងពិធីនានាពាក់ព័ន្ធនឹងជីវៈចម្រុះ ការទូទាត់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងការអភិរក្សក្រៅតំបន់
- បំពេញការងារផ្សេងៗទៀតតាមការស្នើសុំរបស់ប្រធានក្រុមការងារ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

**ប្រការ៤.-**

**ក.ប.ជ.** ត្រូវរៀបចំប្រជុំទៀងទាត់ចំនួន២ដងក្នុង១ឆ្នាំ ដើម្បីពិនិត្យពីវឌ្ឍនភាព និងរៀបចំផែនការរបស់ខ្លួន។ ប្រធាន **ក.ប.ជ.** អាចកោះប្រជុំបន្ថែមតាមការចាំបាច់។ សមាជិក **ក.ប.ជ.** ក៏ត្រូវចូលរួមក្នុងក្រុមពិសេសដែលបង្កើតឡើងដោយ **ក.ប.ជ.** តាមការស្នើសុំរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូបត្រូវដឹកនាំកិច្ចប្រជុំជំនួស តាមការប្រគល់សិទ្ធិពីប្រធាន។ សមាជិក **ក.ប.ជ.** អាចផ្តល់សិទ្ធិទៅអ្នកជំនួសរបស់ខ្លួនពេលអវត្តមាន ដោយជូនដំណឹងទៅប្រធានជាមុន។

តំណាងអង្គការជាតិ-អន្តរជាតិ និងអ្នកពាក់ព័ន្ធ អាចចូលរួមប្រជុំ ក្នុងនាមជាអ្នកសង្កេតការណ៍ និងតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ដើម្បីផ្តល់យោបល់ និងប្រឹក្សាដោយឡែកតាមភាពចាំបាច់។ សមាជិក **ក.ប.ជ.** មានសិទ្ធិស្នើទៅប្រធាន ដើម្បីឱ្យតំណាងអង្គការជាតិ-អន្តរជាតិ និងអ្នកពាក់ព័ន្ធចូលរួមប្រជុំក្នុងនាមជាអ្នកសង្កេតការណ៍។

នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋាន **ក.ជ.អ.ច.** ត្រូវដើរតួនាទីជាលេខាធិការដ្ឋាន នៃ **ក.ប.ជ.** និងមានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

**ប្រការ៥.-**

អនុក្រុមការងារបច្ចេកទេសមួយចំនួន នឹងត្រូវបង្កើតឡើងដោយឡែកក្នុងករណីចាំបាច់ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តពិធីសារណាហ្គូយ៉ាស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ ការអនុវត្តពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព និងការអនុវត្តក្រមបរិស្ថាន និងធនធានធម្មជាតិ។ សមាសភាពប្រធាន អនុប្រធាន និងសមាជិក នៃអនុក្រុមការងារបច្ចេកទេសពិធីសារណាហ្គូយ៉ាស្តីពីការប្រើប្រាស់ និងការបែងចែកផលប្រយោជន៍ពីធនធានពន្ធុ (ABS) អនុក្រុមការងារបច្ចេកទេសពិធីសារ

R. H pr. [illegible]

កាតាហេ្សណាស្តីពីជីវសុវត្ថិភាព (Biosafety) និងអនុក្រុមការងារបច្ចេកទេសពាក់ព័ន្ធនឹងការអនុវត្ត ក្រមបរិស្ថាន និងធនធានធម្មជាតិ ត្រូវជ្រើសចេញពីតំណាងស្ថាប័ន និងអង្គភាពក្នុងប្រការ ២។ ប្រធាន **គ.ប.ជ.** នឹងលើកសំណើសុំការអនុញ្ញាតជាគោលការណ៍ពីប្រធាន **គ.ជ.អ.ច.** ក្នុងការជ្រើសរើសប្រធាន អនុប្រធាន និងសមាជិក នៃអនុក្រុមការងារបច្ចេកទេសមួយចំនួននោះចេញពីសមាសភាពក្រុមការងារបច្ចេកទេសជីវៈចម្រុះ។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយកនៃអគ្គនាយដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គនាយនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នាយកខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុក អនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ៧៨២កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**
**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ